# ប្រាក់ជំនួយ



ក្រសួងនៃការបំរើសហគម នៅស្រុកសាន់តាក្លារ៉ា ផ្តល់នូវការ ការពារ ជីវិត ការគាំទ្រជីវិត និងធ្វើឲ្យការរស់នៅ បានប្រសើរដល់ជន "អន្តោប្រវេសន៍ពេញលក្ខណៈ" មនុស្សពេញវ័យ ក្មេងៗ គ្រួសារ មនុស្សចាស់ និងមនុស្សណា ដែលត្រូវការពឹងផ្អែក ក្នុងស្ថានភាព លុយកាក់។ ទាំងនេះអាចធ្វើទៅបាន ដោយសារជួយអ្នកនោះ ឲ្យបាន ចេះរស់នៅដោយខ្លួនឯង ឲ្យបានទទួលការងារធ្វើ និងទទួលផល ប្រយោជន៍សាធារណៈ ពីកម្មវិធីផ្សេងៗ។

## តើការបំរើសហគម មានកម្មវិធី ប្រាក់ជំនួយអ្វីខ្លះ? ហើយអ្នកណា ដែលអាចទទួលបាន ?

ចំពោះជនអន្តោប្រវេសន៍ ដែលទើបមកដល់ថ្មីៗ កម្មវិធីទាំងនោះ មាន :

- CalWORKs
- ជួយជាទូទៅ ( General Assistance)
- SSI
- CAPI
- ជួយលុយដល់ជនភាសខ្លួន (Refugee Cash Assistance)
- Foster Care
- Kin-GAP, and
- កម្មវិធីសំរាប់ជួយជនភាសខ្លួន ឲ្យបានកន្លែងជ្រកកោន (Refugee Resettlement Program (RRP) )

## តើការទទួលប្រាក់ជំនួយ អាចប៉ះពាល់ ដល់សភាព អន្តោប្រវេសន៍ខ្ញុំយ៉ាងណាខ្លះ?

ទទួលយក ប្រាក់ជំនួយ អាចធ្វើឲ្យប៉ះពាល់ ដល់ភាពអន្តោប្រវេសន៍ បើសិនជា លុយជំនួយនោះ ជាប្រភពតែមួយសំរាប់លុយ ចំណូល ប្រាក់ខែគេ។ បើសិនជាអ្នកមានកាតប៉ៃតងហើយ ប្រាក់ជំនួយមិនអាចប៉ះពាល់ ដល់ភាពអន្តោប្រវេសន៍ អ្នកបានទេ លើកលែងតែអ្នកចាកចេញទៅក្រៅប្រទេសច្រើនជាង ១៨០ថ្ងៃ។ បើសិនជាអ្នកមកដល់ស្រុកនេះក្រោយ ខែសីហា ថ្ងៃទី២២ ឆ្នាំ១៩៩៦ **(August 22, 1996)** អ្នកប្រហែលជាមានបញ្ហា បើសិនជាអ្នក ទទួល លុយជំនួយ ក្នុងរយះប្រាំឆ្នាំដំបូង ក្រោយពេលបានទទួល កាតប៉ៃតង រួចហើយ។

បើសិនជាអ្នកគ្មានកាតប៉ៃតងទេ ការប្រើលុយជំនួយ ជាប្រាក់ចំណូល តែមួយនោះ អាចធ្វើឲ្យការសុំកាតប៉ៃតងរបស់អ្នក មានបញ្ហាបាន។

បើសិនអ្នកជាជនភៀសខ្លួន ជាជនអន្តោប្រវេសន៍ម្នាក់ ដែលការពារ ដោយ ច្បាប់ VAWA ឬជា asylee ការប្រើលុយជំនួយ នោះ មិនអាចប៉ះពាល់ដល់អ្នកទេ។
សូមអាន ទំព័រទី 4 ដើម្បីឲ្យបានពត៌មានបន្ថែម។

## តើ CalWORKs ជាអ្វី ?

CalWORKs មានន័យថា California Work Opportunity and Responsibility to Kids គឺជាឈ្មោះ របស់កម្មវិធី welfare នៃរដ្ឋកាលីហ្វ័រនីញ៉ា នៅប្រទេសសហរដ្ឋ អាមេរិក។ អាចទទួលបាន តែនៅពេលណាដែល កូនក្មេងមិនមាន ការគាំទ្រពីមាតាបិតា ឬដោយសារ ឪពុកឬម្តាយ ឬអ្នកទាំងពីរអត់នៅ ឬស្លាប់ ឬឥតមានកម្លាំងមាំនឹងធ្វើការបាន ឬក៏ឥតមានការងារធ្វើ។ កម្មវិធីនេះជួយមាតាបិតា រកការងារធ្វើ និងរៀបខ្លួន សំរាប់ធ្វើ ការងារ។

## តើអ្នកណាអាចមានសិទ្ធទទួល CalWORKs បាន ?

បើសិនជា អ្នកត្រូវមើលរក្សាក្មេងអាយុតិចជាង ១៩ឆ្នាំនោះ អ្នក ប្រហែលជា អាចទទួល លុយជំនួយពី CalWORKs បាន។ អ្នក ត្រូវតែជា "ជនអន្តោប្រវេសន៍ពេញលក្ខណៈ"** ឬ PRUCOL** និង:

- នៅក្រោមអាយុ១៩ឆ្នាំ ឬ
- ឪពុកម្តាយជាក្មេងជំទង់ ឬ
- មានផ្ទៃពោះ ឬ
- ជាឪពុកម្តាយ ឬជាអ្នកថែរក្សាកូនក្មេង ដែលមានអាយុតិចជាង ១៩ឆ្នាំ។

**សូមអាន ទំព័រទី 3 ដើម្បីឲ្យបានពត៌មានបន្ថែម។



ត្រូវការពត៌មានថែមទៀត? សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីប្តូរថ្មី និងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៤ល្ងាច ហើយជាពីរភាសា អង់គ្លេសនិងភាសាដូចតទៅ :
អេស្ប៉ាញ៉ុល- (408) 286-1698 វៀតណាម- (408) 286-1448 Farsi- (408) 286-5680 x108 និងចិន- (408) 286-5680 x109

## តើកូនខ្ញុំដែល ជាអ្នកមានសញ្ជាតិ អាចទទួល CalWORKs ឬទេ? បើខ្ញុំជាអ្នកឥតមានសញ្ជាតិទេនោះ

CalWORKs តម្រូវឲ្យអ្នកទទួល ជាអ្នកមានលក្ខណៈអន្តោប្រវេសន៍ ឬជាអ្នកមានសញ្ជាតិ។ នៅក្នុងចំណោមគ្រួសារខ្លះ ក្មេងៗ ឬក៏សមាជិកគ្រួសារផ្សេងទៀត អាចទទួលផលប្រយោជន៍បាន បើសិនជាគេកើតនៅសហរដ្ឋអាមេរិក ថ្វីបើមាតាបិតា ឬអ្នកអាណាព្យាបាលមិនអាចទទួលបាន។ ការចូលរួមក្នុង CalWORKs អាចប៉ះពាល់ដល់សភាពអន្តោប្រវេសន៏របស់អ្នក។ សូមអ្នកមើលផ្នែកនៃទំព័រលេខ 3 ដើម្បី ឲ្យបានពត៌មានបន្ថែម។

## តើខ្ញុំអាចទទួលផលប្រយោជន៏ ក្នុងរយៈពេលប៉ុន្មានទៅ ?

សព្វថ្ងៃនេះមានកំណត់ពេលរវាង៦០ខែ ក្នុងមួយជីវិតដើម្បីទទួល CalWORKs។ លើកលែងពីកំណត់នេះបាន ដោយសារតែអ្នកមានការរំលោភបំពានរងគ្រោះនៅក្នុងផ្ទះខ្លួន (Domestic Violence)។ អ្នកអាចទទួលយូរ បានហើយពេលវេលាកំណត់ មិនជាការចាំបាច់។

## បើសិនជាខ្ញុំមានអ្នកធានា តើខ្ញុំអាចសុំ CalWORKs បានឬទេ ?

បើសិនអ្នកធានារបស់អ្នក មានប្រាក់ខែវិញ ប្រាក់ខែរបស់អ្នកធានាប្រហែលអាចនឹងបូកចូល ជាមួយប្រាក់ខែរបស់អ្នក ដើម្បីសម្រេចសេចក្តីក្នុងការទទួល CalWORKs បានឬមិនបាន។ សូមទាក់ទងនឹងអង្គការ ខាងក្រោមនេះ ដើម្បីរៀនឲ្យបានដឹង តើអ្នកនិងអ្នកធានារ អាចមានការប៉ះពាល់អ្វីទេ បើអ្នកទទួលជំនួយ CalWORKs នោះ។

## តើជំនួយអ្វីខ្លះដែល CalWORKs ជួយផ្តល់ ?

CalWORKs ផ្តល់ប្រាក់ជំនួយសំរាប់មនុស្សពេញវ័យ ដើម្បីទុកពេលឲ្យគេអាចរក ការងារ ឬទៅរៀនសូត្រ ឬទៅហ្វឹកហ្វឺនខាងការងារ។ ក្រៅពីចលនាទាំងនេះ គេអាចនឹងផ្តល់ជំនួយ ដល់អ្នកដែលរងគ្រោះដែលគេធ្វើបាប ស្ត្រីដែលមានផ្ទៃពោះ ហើយនឹងមនុស្សពេញវ័យដែលត្រូវថែរក្សាក្មេង ដែលមានអាយុតិចជាងមួយឆ្នាំ ។

គ្រួសារដែលទទួល CalWORKs ជាទូរទៅក៏អាចទទួលបានមេឌីកាល់ នឹងអាចទទួល Food Stamps បានទៀត ។ ជំនួយផ្សេងៗទៀតមាន :

- ការថែរក្សាមើលក្មេង
- ការបំរើអំពី ការរំលោភបំពាន រងគ្រោះ នៅក្នុងផ្ទះខ្លួន **(Domestic Violence)**។
- ការឲ្យឱវាទខាងជម្ងឺផ្លូវចិត្ត
- ការឲ្យឱវាទខាងការប្រើថ្នាំញៀន
- ការជួយ ពីការរៀនសូត្រ សំរាប់ទិញសៀវភៅ គ្រឿងប្រើសំរាប់ធ្វើជាង ចំណាយលើយានជំនិះ ហើយនឹងខោអាវសំរាប់សាលារៀន។



## ខ្ញុំធ្វើពាក្យប្តឹងផ្ទាល់ខ្លួន នៅក្រោម VAWA ជាអ្នករងគ្រោះដោយសារ ការរំលោភបំពាននៅ ក្នុងផ្ទះខ្លួន (Domestic Violence) តើខ្ញុំអាចមាន សិទ្ធទទួលយក CalWORKs បានឬទេ?

ការជួយខ្លួន ឲ្យទីពឹងខ្លួនឯងបាន ក្នុងផ្នែកថវិការ ជាការមួយ សំខាន់បំផុត សំរាប់អ្នករងគ្រោះ ឲ្យបានរួចដោះដៃពីការរំលោភ។ ដោយហេតុនេះហើយ អ្នកអន្តោប្រវេសន៍ ដែលគ្មានក្រដាសស្នាម ត្រូវគេរំលោភ ដែលរៀបការឬក៏លែងលះគ្នា ឬ ក៏មានឪពុកម្តាយជាអ្នកមានសញ្ជាតិឬជាអ្នកអចិន្ត្រៃក្នុងស្រុកអាមេរិក ហើយជាអ្នករំលោភនេះ អ្នកអាចដាក់ពាក្យប្តឹងខ្លួនឯង សុំទាមទារ យកកាតបៃតង រួចហើយ នឹងអាចសុំជំនួយពី CalWORKs ថ្វីបើគេពុំទាន់បានទទួល ច្បាប់រស់នៅត្រឹមត្រូវទេនោះ។ សូមអញ្ជើញមើល ផ្នែក **"អំពើឃោរឃៅក្នុងគ្រួសារ ហើយនឹងក្នុងផ្ទះសម្បែង"** នៅលើទំព័រលេខ 113 ដើម្បីបានដំណឹងបន្ថែម។

*សូមអញ្ជើញរកគេជួយក្នុងថ្ងៃនេះកុំខាន !!*

## ខ្ញុំជាក្មេងវ័យជំទង់ ហើយមានកូន ក្លាយទៅជាឪពុកឬម្តាយ តើខ្ញុំអាចរក ប្រាក់ជំនួយ បានឬទេ?

អ្នកជាឪពុកម្តាយតែនៅវ័យក្មេង អ្នកប្រហែលជាអាចបានទទួល CalWORKs បាន តែអ្នកត្រូវចូលរួមក្នុងការសិក្សារ ឈ្មោះកម្មវិធី Cal-Learn ដើម្បីបានសញ្ញាបត្តិ និង **GED**។

## តើមានកម្មវិធី ប្រាក់ជំនួយ ឯណាទៀតទេ ហើយនរណា ជាអ្នកទទួលបាន?

<u>ចំពោះមនុស្សធំ និងប្តី ប្រពន្ធដែលគ្មានកូន</u>

- ការជួយទូទៅនៅ (GA) នៅក្នុងសង្កាត់មាន ឲ្យលុយជាប្រាក់ខ្ចីសំរាប់ជួយមនុស្សម្នាក់ៗ ឬប្តីប្រពន្ធ ដែលពុំអាចបានទទួលពីកម្មវិធីជំនួយផ្សេងទៀត។ អ្នកដែលសុំ (GA) ទាំងអស់ ត្រូវតែចុះហត្ថលេខា យល់ព្រមសងលុយឲ្យសង្កាត់វិញ នូវលុយជំនួយទាំងអស់។ មនុស្សទាំងនោះអាចទទួលជំនួយ (GA) បានរយះយ៉ាងច្រើនតែ ៣ខែ ទេក្នុងមួយឆ្នាំ។

<u>ចំពោះមនុស្សចាស់ៗ និង អ្នកពិការ</u>

បើសិនជាអ្នកអាយុ ៦៥ ឆ្នាំឡើងលើ ពិការភ្នែក ឬ មានការពិការអ្វីៗនោះ ហើយជាអ្នកមានច្បាប់អន្តោប្រវេសន៍នោះ អ្នកអាចមានសិទ្ធនឹងទទួល ប្រាក់ជំនួយ ដូចតទៅនេះ :

- Supplemental Security Income (SSI) – ជាកម្មវិធីលុយរបស់ប្រទេសអាមេរិក សំរាប់មនុស្សចាស់ ពិការភ្នែក នឹង អ្នកពិការទាំងអស់ ដែលមានច្បាប់រស់នៅក្នុងស្រុកអាមេរិក ពីខែ ឧសភា ថ្ងៃទី ២២ ឆ្នាំ ១៩៩៦ (៨-២២-៩៦)។ អ្នកទទួល (SSI) អាចមានសិទ្ធជាមួយគ្នាទទួលមេឌីកាល់ (Medi-Cal) ហើយប្រហែលអាចទទួលបាននូវការ បំរើជួយនៅផ្ទះដែរ (In-Home Supportive Services)។
- កម្មវិធី ជួយលុយ សំរាប់ជនអន្តោប្រវេសន៍ Cash Assistance Program for Immigrants (CAPI) – ជាលុយដែលជួយពីរដ្ឋ សំរាប់មនុស្សចាស់ អ្នកពិការភ្នែក និង អ្នកពិការមួយរូបៗ ដែលមិនមានលក្ខណៈទទួល នូវប្រាក់ជំនួយសំរាប់មនុស្សចាស់ពី SSI/SSP បាន ដោយសារខ្លួនគ្មានសភាព ជាអ្នកអន្តោប្រវេសន៍ពេញច្បាប់។ អ្នកទទួល CAPI ក៏អាចបានទទួល មេឌីកាល់ និង ហ្វូតស្តាំដែរ។ ត្រូវដាក់ពាក្យសុំដោយឡែកដើម្បីបាន ហ្វូតស្តាំ និង មេឌីកាល់។ អ្នកដែលទទួល CAPI ទាំងអស់ ត្រូវតែចុះហត្ថលេខាថានឹងសង ដល់រដ្ឋវិញ ចំពោះ ប្រាក់ជំនួយណាដែលគេបានទទួលជាមួយគ្នាពី SSI/SSP ពីពេលដែល SSI/SSP បានព្រមឲ្យអ្នក ទទួលជំនួយ។

---

**ដើម្បីឲ្យមានលក្ខណះបានទទួលនូវ CAPI អ្នកត្រូវតែសុំ SSI ហើយមិនបានទទួលការយល់ព្រម។ អ្នកអាចសុំនូវ CAPI និង SSI នៅពេលជាមួយគ្នាបាន ដើម្បីឲ្យអ្នកបានទទួលនូវ CAPI ក្នុងពេលឆាប់នោះ**

---

<u>ចំពោះក្មេងដែលរស់នៅតាមផ្ទះជ្រកកោន Foster Care:</u>

- (Foster Care Program)-កម្មវិធីនៃផ្ទះជ្រកកោន ជាកម្មវិធីលុយ ជំនួយពីប្រទេស និងរដ្ឋ ដែលជួយផ្តល់ចំពោះក្មេងដែលត្រូវការ ហើយគ្រួសារខ្លួនមិនចង់ចិញ្ចឹម និងថែរក្សារគេនោះ។
- Kinship Guardian Assistance (Kin-GAP) Program – ការបំរើរក្មេងដែលបានចេញពីផ្ទះជ្រកកោន (Foster Care) ហើយទៅនៅ ជាមួយបងប្អូនខ្លួន។ កម្មវិធីនេះមានបំណង នឹងឲ្យបងប្អូន ដែល ជួយថែរក្សាចិញ្ចឹមនោះ បានទទួលជំនួយលុយកាក់ខ្លះៗ។

<u>ចំពោះជនភាសខ្លួន (Refugees):</u>

- Refugee Resettlement Program (RRP) – ជាកម្មវិធី របស់ប្រទេសដែលឲ្យលុយជំនួយ និងជួយការព្យាបាលពេទ្យ សំរាប់ជនភាសខ្លួន។ RRP មានជួយប្រាក់ជំនួយដែរ ក្នុងការរកការងារធ្វើ បង្រៀនធ្វើការងារ ដោយផ្តល់តាមកម្មវិធី ដូចជា Targeted Assistance Program (TAP) ហើយនឹង កម្មវិធី

Refugee Employment Social Services (RESS) ។

- ○ ជនភាសខ្លួនមនុស្សធំ ដែលមានកូនចៅ ហើយ ប្រាក់ខែខ្លួន មានតំរូវតាមកំណត់នោះប្រហែល អាចសុំ CalWORKs បានដែរ។
- ○ ជនភាសខ្លួនមនុស្សធំ ដែលគ្មានគ្រួសារ ប្រហែល ជាអាចបានទទួលនូវ Refugee Cash Assistance (RCA) ពេលរយះ ៨ ខែដែលមក នៅស្រុកអាមេរិកដំបូង។ មនុស្សធំដែលពុំអាចបាន ទទួល RCA ប្រហែលជាអាចបានទទួលនូវ ជំនួយទូទៅ (General Assistance) បាន។

**American Red Cross – Palo Alto**
400 Mitchell Lane, Palo Alto, CA 94301
Tel: (650) 688-0415

ភាសា: អេស្ប៉ាញ៉ូល
ការបំរើ: ការផ្តល់តែក្នុងមួយដង នូវប្រាក់ជំនួយថ្លៃជួលផ្ទះ ដល់មនុស្សម្នាក់ៗ និងគ្រួសារ ដែលមានលក្ខណះទទួលបាន ដើម្បីការពារកុំឲ្យទៅជាមនុស្សអត់ផ្ទះសំបែង។ ក៏អាចផ្តល់ជួយ នូវថ្លៃទឹកភ្លើង ទូរសព្ទដែរ។ ការជួយ មានឲ្យតែលេខ zip code areas ដូចតទៅ : 94301, 94303, 94304, 94305, 94306។

**American Red Cross – Santa Clara Valley**
2731 N. First St., San Jose, CA 95134
Tel: (408) 577-1000

ភាសា: ចិន បារាំង អ៊ីតាលី ជប៉ុន Greek, Portuguese អេស្ប៉ាញ៉ូល និង វៀតណាម។
ការបំរើ: ការផ្តល់តែក្នុងមួយដង នូវប្រាក់ជំនួយថ្លៃជួលផ្ទះ ដល់មនុស្សម្នាក់ៗ និងគ្រួសារ ដែលមានលក្ខណះទទួលបាន ដើម្បីការពារ កុំឲ្យទៅជាមនុស្សអត់ផ្ទះសំបែង។ ក៏អាចផ្តល់ជួយ នូវថ្លៃទឹកភ្លើង ទូរសព្ទដែរ។ ការជួយ មានឲ្យតែលេខ zip code areas ដូចតទៅ : 95002, 95035, 95050, 95051, 95053, 95054, 95116, 95122, 95127, 95131, 95132, 95133, 95134, 95140, 95148។

**California Employment Development Department (EDD) Unemployment Insurance Office**
សុំលុយ និង ពត៌មាន ពេលអស់ការងារធ្វើ

Information and Filing of Unemployment Claims:
TDD (408) 298-5443 (DCARA)
ចំពោះកន្លែងជិតអ្នក សូមទូរស័ព្ទ : 1(800) 300-5616.

ការបំរើ: ផ្តល់លុយជួយ ដល់អ្នកអស់ការងារ រាល់អាទិត្យ (cash payments) ផ្ញើរទៅឲ្យពីរអាទិត្យម្តង ចំពោះអ្នកដែលមានលក្ខណះទទួលបាន ដែលគ្មានការធ្វើ។ សាធារណះជនអាច សុំផលប្រយោជន៍ នេះបាន តាមទូរស័ព្ទ ដែលមានលេខដូចខាងលើ។

កន្លែងខាងក្រោមនេះ មានបើកសំរាប់ តែអ្នកដែលចង់រកការងារធ្វើ តែប៉ុណ្ណោះ មិនមែនកន្លែងសុំលុយក្រោយអស់ការងារទេ។

**Community Services Agency of Mountain View and Los Altos**
204 Stierlin Rd., Mountain View, CA 94043
Tel: (650) 968-0836

ភាសា: Hindi, Marathi អេស្ប៉ាញ៉ូល Tagalog និង Tamil។
ការបំរើ: ផ្តល់ជំនួយក្នុងគ្រាអាស័ន្ន ដូចជា ជួយក្នុងការជួលផ្ទះ និង ជួយនូវថ្លៃទឹកភ្លើង ទូរសព្ទ ដល់អ្នកត្រូវការជាខ្លាំង ហើយមានលក្ខណះទទួលបាន។ ការជួយ មានឲ្យតែលេខ zip code areas ដូចតទៅ : 94022, 94024, 94035, 94040, 94041, 94043 ។

**Cupertino Community Services**
10185 N. Stelling Rd., Cupertino, CA 95014
Tel: (408) 255-8033

ភាសា: អេស្ប៉ាញ៉ូល
ការបំរើ: ផ្តល់ជំនួយក្នុងគ្រាអាស័ន្ន ដើម្បីការពារកុំឲ្យក្លាយទៅជាអ្នកអត់មាន ផ្ទះសម្បែង។ ការជួយ មានឲ្យតែលេខ ដែលនៅក្នុងដំបន់ដូតតទៅ : Cupertino, Los Gatos, Saratoga, and some West San Jose zip codes: 95129, 95130, 95070, 95030, 95014, 95032, 95033, 95044

**ESO Home Emergency Assistance Programs**
1445 Oakland Rd., San Jose, CA 95112
Tel: (408) 971-2560
*(continued…)*

ការបំរើ: ការធ្វើឲ្យបានល្អប្រសើរ នូវសុខភាព និង សេចក្តីសុខ ការធ្វើឲ្យបានល្អប្រសើរ នូវការប្រើកម្លាំងភ្លើងអគ្គិសនី ការជួលជុលផ្ទះបន្តិចបន្តួច ការដាក់ភ្លើង និងការសិក្សាអំពី ការចេះសំចៃនូវការប្រើកម្លាំងភ្លើង។

**Sacred Heart Community Services**
1381 S. First St. (Alma), San Jose, CA 95110
Tel: (408) 283-5800

ភាសា: អេស្ប៉ាញ៉ុល
ការបំរើ: ការផ្តល់តែក្នុងមួយដង នូវប្រាក់ជំនួយថ្លៃជួលផ្ទះ ដល់មនុស្សម្នាក់ៗ និងគ្រួសារ ដែលមានលក្ខណះទទួលបាន ដើម្បីការពារកុំឲ្យទៅជាមនុស្សអត់ផ្ទះសំបែង។ ក៏អាចផ្តល់ជួយ នូវថ្លៃទឹកភ្លើង និងទូរសព្ទដែរ។ ការជួយ មានឲ្យតែលេខ zip code areas ដូចតទៅ : 95008, 95110, 95117, 95118, 95124, 95125

**Salvation Army**
359 N. Fourth St., San Jose, CA 95110
Tel: (408) 282-1165

ភាសា: អេស្ប៉ាញ៉ុល និង Tagalog
ការបំរើ: ការផ្តល់តែក្នុងមួយដង នូវប្រាក់ជំនួយថ្លៃជួលផ្ទះ ដល់មនុស្សម្នាក់ៗ និងគ្រួសារ ដែលមានសិទ្ធទទួលបាន ដើម្បីការពារកុំឲ្យទៅជាមនុស្សអត់ផ្ទះសំបែង។ ក៏អាចផ្តល់ជួយ នូវថ្លៃទឹកភ្លើង និងទូរសព្ទដែរ។ ការជួយ មានឲ្យតែលេខ zip code areas ដូចតទៅ : 95013, 95037, 95111, 95112, 95113, 95119, 95120, 95121, 95123, 95126, 95128, 95135, 95136, 95137, 95138, 95239, 95141, 95192

**Santa Clara County Bar Association Law Foundation (Mental Health Advocacy)**
111 W St John St., Suite 315, San Jose, CA 95113
Tel: (408) 294-9730

ភាសា: អេស្ប៉ាញ៉ុល វៀតណាម
ការបំរើ: ការផ្តល់នូវជំនួយ ដល់មនុស្សមាន ជម្ងឺផ្លូវចិត្តនិង ក្រុមពិការ ឲ្យបានប្រសើរ ពីផ្នែកជំនួយអំពីរដ្ឋាភិបាល (SSA and SSI)។

**Services Immigrant Rights & Education Network (SIREN)**
778 N. First St., #202, San Jose, CA 95112
Tel: (408) 286-5680

ការជំនួយរបស់អន្តោប្រវេសន៍ & ពត៌មានទាក់ទង :

អេស្ប៉ាញ៉ុល (408) 286-1698

វៀតណាម (408) 286-1448

Farsi (408) 286-5680 x 108

ចិន (408) 286-5680 x 109

Website: www.siren-bayarea.org

ភាសា: អេស្ប៉ាញ៉ុល វៀតណាម Farsi និង ចិន
ការបំរើ: លេខទូរសព្ទ ដែលឲ្យពត៌មាន និងការបញ្ជូនបន្ត ដែលមានការទាក់ទង នឹងប្រយោជន៏សាធារណះ ការសិក្សាពី សហគមអំពី ប្រយោជន៏សាធារណះ ការឃោសនាដើម្បីដូរ ច្បាប់អ្វីមួយ។ ការ ជួយបង្ហាត់បង្រៀន អំពីភាពអន្តោប្រវេសន៍ និងរឿងរ៉ាវដែលទាក់ទងគ្នា។

**Social Security Adminstration/ SSI**
To schedule an appointment call between 7AM-7PM: 1(800) 772-1213
ការបំរើ: ប្រាក់ជំនួយដល់មនុស្សចាស់ និងអ្នកពិការ ដែលមានសិទ្ធទទួលបាន។

Campbell Office:
770 W. Hamilton Ave., Campbell, CA

<u>ភាសា:</u> អង់គ្លេស អេស្ប៉ាញ៉ុល ជប៉ុន និង អាឡឺម៉ង់។

<u>East San Jose Office:</u>

2726 Aborn Rd., San Jose, CA

<u>ភាសា:</u> អេស្ប៉ាញ៉ុល វៀតណាម Portuguese និង អង់គ្លេស

<u>South San Jose:</u>

6140 Cottle Rd., San Jose, CA

<u>ភាសា:</u> អេស្ប៉ាញ៉ុល វៀតណាម និង អង់គ្លេស។

<u>Sunnyvale Office:</u>

438 S. Murphy Ave., Sunnyvale, CA

<u>ភាសា:</u> អេស្ប៉ាញ៉ុល វៀតណាម និង អង់គ្លេស។

<u>Downtown San Jose:</u>

280 S. 1st. St., San Jose, CA

<u>ភាសា:</u> អេស្ប៉ាញ៉ុល វៀតណាម និង Tagalog។

**Social Services Agency General Assistance/CAPI (Cash Assistance Program for Immigrants)**
591 N. King Rd., San Jose, CA 95133
Tel: (408) 928-3650

*(continued…)*

<u>ភាសា:</u> Amharic, ចិនCantonese, Farsi, ចិនMandarin រុស្ស៊ី អេស្ប៉ាញ៉ុល វៀតណាម និងមានការបំរើ ក្នុងការបកប្រែគ្រប់ប្រែភាសា ទាំងអស់ផ្សេងៗទៀត។

<u>ការបំរើ:</u> មានលុយជួយដល់អ្នកចាស់ជរា អ្នកពិការ និងមនុស្សធំដែលអត់មានកូន។

## ***<u>Social Services Agency Regional Offices</u>***

**<u>Santa Clara: Mission City</u>**
1800 Pruneridge Ave., Santa Clara, CA 95050
Tel: (408) 556-1700

<u>ភាសា:</u> វៀតណាម អេស្ប៉ាញ៉ុល និង រុស្ស៊ី

<u>ការបំរើ:</u> ហ្វូតស្តាំ និង មេឌីកាល។

**<u>North County: L'Avenida</u>**
1110 L'Avenida, Mountain View, CA 94043
Tel: (650) 314- 1300

<u>ភាសា:</u> ចិន Cantonese, Hindu, ចិន Mandarin, អេស្ប៉ាញ៉ុល រុស្ស៊ី វៀតណាម។

<u>ការបំរើ:</u> ការដាក់ពាក្យសុំយក CalWORKS ហ្វូតស្តាំ ការបន្តនូវ CalWORKs ការបំរើអំពីការងារ។

**<u>North County: Moffett</u>**
100 Moffett Blvd., Mountain View, CA 94043
Tel: (650) 988-6100

<u>ភាសា:</u> អេស្ប៉ាញ៉ុល

<u>ការបំរើ:</u> ហ្វូតស្តាំ និង មេឌីកាល។

**<u>East Valley- Las Plumas</u>**
1670 Las Plumas Ave, Suite H, San Jose, CA 95133
Tel: (408) 928-3101

<u>ភាសា:</u> ការបំរើក្នុងការបកប្រែភាសា ទាំងអស់។

<u>ការបំរើ:</u> ការដាក់ពាក្យសុំយក **CalWORKS** ហ្វូតស្តាំ និង មេឌីកាល។

**<u>San Jose</u>**
1870 Senter Rd., San Jose, CA, 95112
Tel: (408) 999-6330

<u>ភាសា:</u> ការបំរើក្នុងការបកប្រែភាសា ទាំងអស់។

<u>ការបំរើ:</u> ការដាក់ពាក្យសុំយក **CalWORKS** ហ្វូតស្តាំ និង មេឌីកាល។

**<u>San Jose: CalWORKs</u>**
CalWORKS Eemployment and Benefits Agency
1885 Senter Rd, San Jose, CA 95112
Tel: (408) 278-6500

<u>ភាសា:</u> ការបំរើក្នុងការបកប្រែភាសា។
<u>ការបំរើ:</u> CalWORKS

**<u>San Jose: Assistance Application Center</u>**
1919 Senter Rd., San Jose, CA 95112
Tel: (408) 271-5600

<u>ភាសា:</u> យកបាន នូវការបំរើក្នុងការបកប្រែភាសា ទាំងអស់។
<u>ការបំរើ:</u> ការដាក់ពាក្យសុំយក **CalWORKS** ហ្វូតស្តាំ និង មេឌីកាល។

**<u>South County: Leavesley CalWORKS</u>**
190 Leavesley Rd., Gilroy, CA 95020
Tel: (408) 846-3900

<u>ភាសា:</u> យកបាន នូវការបំរើក្នុងការបកប្រែភាសា ទាំងអស់។
<u>ការបំរើ:</u> ការដាក់ពាក្យសុំយក **CalWORKS** និងការបំរើរបស់ **CalWORKS** ។

**<u>South County: Highland</u>**
80 Highland Ave., San Martin, CA 95046
Tel: (408) 686-8700
(408) 683-0915



ត្រូវការពត៌មានថែមទៀត? សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីប្តូរថ្មី និងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៨ល្ងាច ហើយជាពីរភាសា អង់គ្លេសនិងភាសាដូចតទៅ :
អេស្ប៉ាញ៉ុល- (408) 286-1698 វៀតណាម- (408) 286-1448 **Farsi**- (408) 286-5680 x108 និងចិន- (408) 286-5680 x109